ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
អគ្គនាយកដ្ឋានសំណង់

# ការគ្រប់គ្រងវិស័យសំណង់

បណ្ឌិត ឆាន់ សុរ្យផល អគ្គនាយក នៃអគ្គនាយកដ្ឋានសំណង់

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែវិច្ឆកា ឆ្នាំ២០២៣

# មាតិកា

1. សាវតា និងអាជ្ញាធរមានសមត្ថកិច្ច
2. សមត្ថកិច្ចអគ្គនាយកដ្ឋានសំណង់
3. លិខិតបទដ្ឋានគតិយុត្តក្នុងការផ្តល់សេវាសាធារណៈ
4. ការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់
5. ការគ្រប់គ្រងការដ្ឋានសំណង់
6. ការកសាងគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត
7. បរិវត្តកម្មឌីជីថលក្នុងវិស័យសំណង់

# សាវតា និងអាជ្ញាធរមានសមត្ថកិច្ច

# សាវតារអគ្គនាយកដ្ឋានសំណង់

- រហូតដល់ឆ្នាំ១៩៧៥ វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានគ្រប់គ្រងដោយ នាយកដ្ឋាននគរូបនីយកម្មនិងលំនៅឋាន នៃក្រសួងសាធារណៈការ
- ក្រោយថ្ងៃរំដោះ៧ មករា ១៩៧៩ មន្ទីររៀបចំក្រុង ត្រូវបានបង្កើតនៅក្រុងភ្នំពេញ និងការិយាល័យសំណង់ ត្រូវបានបង្កើតនៅតាមបណ្ដាខេត្ត ដោយនៅខេត្តខ្លះត្រូវដាក់ឱ្យស្ថិតនៅក្រោមមន្ទីរផែនការ និងនៅខេត្តខ្លះទៀតក្រោមមន្ទីរឧស្សាហកម្ម។សហគ្រាសសំណង់មួយក៏ត្រូវបានបង្កើតឡើងនិងស្ថិតនៅក្រោមក្រសួងឧស្សាហកម្មដើម្បីសាងសង់សំណង់របស់រដ្ឋនៅទូទាំងប្រទេស
- ឆ្នាំ ១៩៨៦ ដោយវិស័យសំណង់មានការរីកចម្រើន អគ្គនាយកដ្ឋានសំណង់ ត្រូវបានបង្កើតឡើងស្ថិតនៅចំណុះក្រុមប្រឹក្សារដ្ឋមន្ត្រី
- ឆ្នាំ ១៩៩៣ រាជរដ្ឋាភិបាលនីតិកាលទី១នៃរដ្ឋសភា អគ្គនាយកដ្ឋានសំណង់ ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមក្រសួងសាធារណៈការ និងដឹកជញ្ជូន
- ឆ្នាំ ១៩៩៤ វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានដឹកនាំនិងគ្រប់គ្រងដោយគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ដែលមានទីស្នាក់ការនៅទីស្ដីការគណៈរដ្ឋមន្ត្រី
- ឆ្នាំ ១៩៩៨ ការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវបានផ្ដួចផ្ដើមឡើងដោយ **សម្ដេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន**
- ឆ្នាំ ១៩៩៩ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវបានបង្កើតឡើងតាមរយៈច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលត្រូវបានចូលជាធរមានតាមព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដោយទទួលបេសកកម្មដឹកនាំ និងគ្រប់គ្រងការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រ។

# អាជ្ញាធរមានសមត្ថកិច្ចគ្រប់គ្រងវិស័យសំណង់

- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចគ្រប់គ្រងវិស័យសំណង់

- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចប្រគល់ឬធ្វើប្រតិភូកម្មសមត្ថកិច្ចគ្រប់គ្រងវិស័យសំណង់ដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**អាជ្ញាធរមានសមត្ថកិច្ចថ្នាក់ជាតិ**
រដ្ឋមន្ត្រី

**មន្ត្រីមានសមត្ថកិច្ចថ្នាក់ជាតិ**
អគ្គនាយកសំណង់

**អាជ្ញាធរមានសមត្ថកិច្ចថ្នាក់រាជធានី ខេត្ត**
អភិបាលរាជធានី ខេត្ត

**មន្ត្រីមានសមត្ថកិច្ចថ្នាក់រាជធានី ខេត្ត**
ប្រធានមន្ទីរ ដ.ន.ស.ស. រាជធានី ខេត្ត

**អាជ្ញាធរមានសមត្ថកិច្ចថ្នាក់ក្រុង ស្រុក ខណ្ឌ**
អភិបាលក្រុង ស្រុក ខណ្ឌ

**មន្ត្រីមានសមត្ថកិច្ចថ្នាក់ក្រុង ស្រុក ខណ្ឌ**
ប្រធានការិយាល័យ ដ.ន.ស.ភ. នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ

# ប្រវត្តនៃការគ្រប់គ្រងវិស័យសំណង់

**១៩៩៤**

ព្រះរាជក្រមលេខ
០៤/នស/៩៤
ច្បាប់ស្តីពីការរៀបចំទឹកដី
នគរូបនីយកម្ម និងសំណង់

**១៩៩៧**

អនុក្រឹត្យលេខ ៨៦ អនក្រ.បក
ស្តីពីលិខិតអនុញ្ញាតសាងសង់
ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧

**១៩៩៩**

អនុក្រឹត្យលេខ ៦២ អនក្រ.បក
ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួង ដនស
ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩

**២០១៥**

អនុក្រឹត្យលេខ ៤២ អនក្រ.បក
ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥

**២០១៩**

ព្រះរាជក្រមលេខ
នស/រកម/១១១៩/០១៩
ច្បាប់ស្តីសំណង់
ចុះថ្ងៃទី០២ ខែវិច្ឆកា ឆ្នាំ២០១៩

**២០២០**

អនុក្រឹត្យលេខ ២២៤ អនក្រ.បក
ស្តីពីលិខិតអនុញ្ញាតសាងសង់
ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

**២០២២**

ប្រកាសលេខ ០១៣ នសន/ប្រក/នី.ក
ស្តីពីបែបបទនិងបរិបថនៃការផ្តល់លិខិត
អនុញ្ញាតសាងសង់
ដោយរដ្ឋមន្ត្រីក្រសួង ដនស
ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២២

និរាករណ៍

ការគ្រប់គ្រងអ្នកវិជ្ជាជីវៈ

អធិការកិច្ចសំណង់

# សមត្ថកិច្ចអគ្គនាយកដ្ឋានសំណង់

# រចនាសម្ព័ន្ធអគ្គនាយកដ្ឋានសំណង់

**អគ្គនាយក ១ រូប**
**អគ្គនាយករង ៥ រូប**

## នាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់

ការិយាល័យបទដ្ឋាន និងបទប្បញ្ញត្តិវិស្វកម្ម
ការិយាល័យបទដ្ឋាន និងបទប្បញ្ញត្តិស្ថាបត្យកម្ម
ការិយាល័យកិច្ចការទូទៅ ព័ត៌មានវិទ្យា និងឯកសារ

- ស្រាវជ្រាវ រៀបចំបទប្បញ្ញត្តិ ទម្រង់បែបបទ ក្បួនខ្នាត លក្ខណៈវិនិច្ឆ័យបច្ចេកទេស បច្ចេកវិទ្យា បទដ្ឋានបច្ចេកទេសសំណង់ និងស្ថាបត្យកម្ម រួមទាំងស្តង់ដាសម្ភារៈ បរិក្ខារសំណង់ឱ្យបានឯកភាព
- ត្រួតពិនិត្យ និងដាក់ឱ្យធ្វើការពិសោធន៍សម្ភារៈសំណង់
- សម្របសម្រួលជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## នាយកដ្ឋានសិក្សាគម្រោងប្លង់

ការិយាល័យស្ថាបត្យកម្ម
ការិយាល័យបែបបទអាជីវកម្ម
ការិយាល័យវិស្វកម្ម និងកិច្ចការតម្លៃ

- គ្រប់គ្រង ពិនិត្យ កំណត់សមត្ថភាពបច្ចេកវិជ្ជាជីវៈ និងចេញលិខិតអនុញ្ញាតអាជីវកម្មដល់រូបវន្តបុគ្គល និងនីតិបុគ្គលដែលធ្វើអាជីវកម្មទាក់ទងនឹងការសាងសង់ និងការសិក្សាគម្រោងប្លង់
- លើកយោបល់លើការស្នើសុំលិខិតអនុញ្ញាតសាងសង់

## នាយកដ្ឋានសំណង់

ការិយាល័យជួសជុល និងថែទាំ
ការិយាល័យបទប្បញ្ញត្តិការងារការដ្ឋាន
ការិយាល័យបច្ចេកទេស និងត្រួតពិនិត្យ

- តាមដាន ត្រួតពិនិត្យការសាងសង់ ការជួសជុល ការថែទាំ ការរុះរើរាល់បណ្តាគម្រោងសំណង់អគាររបស់រដ្ឋ ឯកជន អង្គការនានា រួមទាំងសំណង់បេតិកភណ្ឌ និងសំណង់ផ្សេងៗទៀត
- លើកយោបល់លើការស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋាន បិទការដ្ឋានជួសជុលនិងរុះរើសំណង់

# កំណែទម្រង់ការគ្រប់គ្រងវិស័យសំណង់បច្ចុប្បន្ន



# ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងវិស័យសំណង់

## ➢ គោលនយោបាយនិងច្បាប់

- ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ដែលប្រកាសដាក់ឱ្យប្រើដោយព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ១៩៩៤
- ច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលត្រូវបានចូលជាធរមានតាមព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩
- ច្បាប់ស្តីពីសំណង់ ដែលប្រកាសដាក់ឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩

## ➢ លិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ សម្រាប់គ្រប់គ្រងវិស័យសំណង់ មាន

| | |
|---|---|
| • អនុក្រឹត្យ | ចំនួន ១២ |
| • សារាចរណែនាំរបស់រាជរដ្ឋាភិបាល | ចំនួន ០១ |
| • ប្រកាសអន្តរក្រសួង | ចំនួន ០៩ |
| • ប្រកាសក្រសួង | ចំនួន ២០ |
| • សារាចរណែនាំរបស់ក្រសួង | ចំនួន ០២ |
| • សេចក្តីសម្រេច | ចំនួន ០៣ |
| • សេចក្តីណែនាំ | ចំនួន ០៦ |
| • សេចក្តីជូនដំណឹង | ចំនួន ០៤ |
| • លិខិតណែនាំ | ចំនួន ២៣ |






# និយមន័យសំណង់

- សំណង់
  - ការងារសំណង់ (ដំណើរការ)
    - ការងារសិក្សាគម្រោងប្លង់
    - ការងារវាស់វែង
    - ការងារសាងសង់
      - ការងារដី
      - ការងារសាងសង់ថ្មី
      - ការងារជួសជុល
      - ការងារកែប្រែ
      - ការងារដំឡើង
      - ការងារបង្ហើយ
    - ការងាររុះរើ
    - ការងារគ្រប់គ្រងការដ្ឋាន
    - ការងារត្រួតពិនិត្យនិងបញ្ជាក់
    - ការងារសិក្សាពិសោធន៍
    - ការងារគ្រប់គ្រងគម្រោងសាងសង់
    - ការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់
  - សំណង់ (គ្រឿងផ្គុំ)
    - សំណង់អគារ
    - សំណង់មិនមែនអគារ

# ដំណើរការស្នើសុំលិខិតអនុញ្ញាត



# ការត្រួតពិនិត្យការងារសំណង់



# ប្រព័ន្ធការងារត្រួតពិនិត្យការងារសំណង់

| | | | |
|---|---|---|---|
| ដំណាក់កាលទី១ | សិក្សាគម្រោងប្លង់ស្ថាបត្យកម្ម | ត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់ស្ថាបត្យកម្ម | ស្នើសុំលិខិតអនុញ្ញាតសាងសង់ |
| ដំណាក់កាលទី២ | -សិក្សាគម្រោងប្លង់គ្រឿងផ្គុំ<br>-សិក្សាគម្រោងប្លង់ MEP | ត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់គ្រឿងផ្គុំ និង គម្រោងប្លង់ MEP | ស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ |
| ដំណាក់កាលទី៣ | ចាប់ផ្តើមដំណើរការសាងសង់ | ត្រួតពិនិត្យនិងបញ្ជាក់លើការងារសាងសង់ | ស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ |
| ដំណាក់កាលទី៤ | | | |

**ការត្រួតពិនិត្យជាទៀងទាត់( មាត្រា៤៧):**

➔ ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាព:

- សំណង់លំនៅឋាន : យ៉ាងតិច ១០ឆ្នាំម្តង
- សំណង់មិនមែនលំនៅឋាន : យ៉ាងតិច ៥ឆ្នាំម្តង

➔ ការត្រួតពិនិត្យប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យ : យ៉ាងតិច ២ឆ្នាំម្តង

➔ ការត្រួតពិនិត្យបរិក្ខារសំណង់ដែលងាយបង្កគ្រោះថ្នាក់ : យ៉ាងតិច ១ឆ្នាំម្តង

# ការត្រួតពិនិត្យការងារសំណង់

- បទប្បញ្ញត្តិក្នុងវិស័យសំណង់
  - បទប្បញ្ញត្តិនគរូបនីយកម្ម
  - បទប្បញ្ញត្តិបច្ចេកទេសសំណង់
    - បទប្បញ្ញត្តិស្ថាបត្យកម្ម
    - បទប្បញ្ញត្តិវិស្វកម្ម
  - បទប្បញ្ញត្តិគតិយុត្តដទៃទៀត

# លិខិតបទដ្ឋានគតិយុត្តក្នុងការផ្តល់សេវាសាធារណៈ

# លិខិតបទដ្ឋានគតិយុត្តសម្រាប់ការងារផ្តល់លិខិតអនុញ្ញាតសាងសង់

ការសាងសង់ឬការកែប្រែសំណង់ ត្រូវបានច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ កំណត់ឱ្យមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចតាំងពីឆ្នាំ១៩៩៤ ប៉ុន្តែការអនុវត្តបញ្ញត្តិនេះត្រូវកំណត់ដោយអនុក្រឹត្យ។ រយៈពេល៣ឆ្នាំក្រោយ គឺនៅឆ្នាំ១៩៩៧ ទើប “**អនុក្រឹត្យលេខ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់**” បានត្រូវអនុម័តនិងដាក់ឱ្យប្រើប្រាស់។ មានន័យថា នៅមុនថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ការសាងសង់សំណង់អគារ មិនទាន់មានលិខិតបទដ្ឋានគតិយុត្តធ្វើការកំណត់ពីលក្ខខណ្ឌ នីតិវិធី និងបែបបទសម្រាប់ឱ្យម្ចាស់សំណង់ដាក់ពាក្យស្នើសុំការអនុញ្ញាតច្បាប់ពីអាជ្ញាធរមានសមត្ថកិច្ចនោះទេ។

ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារផ្តល់លិខិតអនុញ្ញាតសាងសង់រួមមាន÷

- ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៤
- ច្បាប់ស្តីពីសំណង់ឆ្នាំ២០១៩
- អនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់
- អនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០០ ស្តីពីការប្រើប្រាស់ដីធ្លី និងសំណង់ នៅតំបន់សៀមរាប-អង្គរ
- អនុក្រឹត្យលេខ៣៩ អនក្រ.បក ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបុរី
- អនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន

# លិខិតបទដ្ឋានគតិយុត្តសម្រាប់ការងារផ្តល់លិខិតអនុញ្ញាតសាងសង់

- អនុក្រឹត្យលេខ២២៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ២០២០ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់
- សារាចរណែនាំលេខ០១ សរណន ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា
- ប្រកាសលេខ២១៧ ប្រក.ដ.ន.ស ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធានគណនាសន្ទស្សន៍ប្រើប្រាស់ដី
- ប្រកាសអន្តរក្រសួងលេខ២៤៨ ស.អ.យ.ប្រក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យអនុវត្តនូវបទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព
- ប្រកាសលេខ០១៣ ដនស/ប្រ.ក/នី.ក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២២ ស្តីពីបែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ប្រកាសលេខ០៩៦ ដនស/ប្រ.ក/នី.ក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២២ ស្តីពីការកែសម្រួលចំណុចទី៧ និងទី៨ ក្នុងប្រការ៣ នៃប្រកាសលេខ០១៣ ដនស/ប្រ.ក/នី.ក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២២ ស្តីពីបែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- សេចក្តីណែនាំលេខ០០១ សនណ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការរៀបចំនិងត្រួតពិនិត្យសំណុំឯកសារសុំលិខិតអនុញ្ញាតសាងសង់សម្រាប់មន្ទីរ ដនសស ខេត្ត ក្រុង

# លិខិតបទដ្ឋានគតិយុត្តសម្រាប់ការងារផ្តល់លិខិតអនុញ្ញាតសាងសង់

- សេចក្តីណែនាំលេខ០១១ ដនស/ប្រ.ច/សណន ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការផ្តល់សេវារដ្ឋបាលផ្នែកសំណង់ ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបមិនលើសពី ៥០០ម២ និងមានកម្ពស់មិនលើសពី ៤ជាន់ រួមទាំងជាន់ផ្ទាល់ដី (E0 E1 E2 E3) នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- សេចក្តីណែនាំលេខ០០២ ដនស/សណន ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ ស្តីពីការពង្រឹងគុណភាពនិងសុវត្ថិភាពសំណង់
- សេចក្តីណែនាំលេខ០០១ ដនស/សណន ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ស្តីពីការលើកកម្ពស់សោភណ្ឌភាពនិងបរិស្ថាន ការរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលចំពោះជនមានពិការភាព និងការរៀបចំប្រអប់សំបុត្រនៅតាមគម្រោងអភិវឌ្ឍន៍ដី គម្រោងសាងសង់ និងសំណង់
- លិខិតលេខ១១៨៣ ដ.ន.ស./អដន ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៤ ស្តីពីការស្នើសុំលិខិតអនុញ្ញាតស្ថានីយប្រេងឥន្ធនៈនៅតាមបណ្តារាជធានី-ខេត្ត
- លិខិតលេខ១៤៤៥ ដនស ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការកំណត់ឆ្លាតម្លាតនគរូបនីយកម្មចំពោះសំណង់មានកម្ពស់ខ្ពស់
- លិខិតលេខ៣០៧៦ ដនស/អរប ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការចូលរួមកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ (តម្រូវឱ្យរៀបចំជម្រាលជនពិការ)
- លិខិតលេខ១៩៣០ ដនស/គដនជ. ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៨ ស្តីពីការកំណត់កម្ពស់ជាន់នីមួយៗនៃអគាររោងចក្រវាយនភណ្ឌ
- **លិខិតលេខ២២៣៥ ដនស/អដន ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៨ ស្តីពីតម្រូវការគិលានដ្ឋានអចិន្ត្រៃយ៍នៅក្នុងរោងចក្រ សហគ្រាស និងគ្រឹះស្ថាននានា**
- លិខិតលេខ២២៥៦ ដនស/គ.អ.ធ.ក ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩ ស្តីពីសេចក្តីណែនាំនិងវិធានការស្តីពីការរៀបចំអាងប្រព្រឹត្តកម្មទឹកកខ្វក់ អាងបង្គន់អនាម័យ និងប្រព័ន្ធលូសម្រាប់រាល់សំណង់អគារលំនៅឋាន ពាណិជ្ជកម្ម សេវាកម្ម សណ្ឋាគារ ភោជនីយដ្ឋាន និងរោងចក្រដែលមានស្រាប់ និង/ឬគម្រោងសាងសង់ថ្មី នៅខេត្តព្រះសីហនុ
- លិខិតលេខ១៥៣៨ ដនស/អរប/នីក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ ស្តីពីការពង្រឹងការអនុវត្តបទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព
- **សេចក្តីជូនដំណឹងលេខ០០១ ដនស/សជណ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យអនុវត្តការត្រួតពិនិត្យនិងបញ្ជាក់សំណង់។**

# លិខិតបទដ្ឋានគតិយុត្តសម្រាប់ការងារផ្តល់លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបិទការដ្ឋាន

បន្ទាប់ពីរាជរដ្ឋាភិបាលបានអនុម័តដាក់ឱ្យប្រើប្រាស់អនុក្រឹត្យលេខ៨៦ នៅឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់ ដែលបានតម្រូវឱ្យម្ចាស់សំណង់មានលិខិតអនុញ្ញាតសាងសង់ និងលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ មុននឹងចាប់ផ្តើមការងារសាងសង់នៅការដ្ឋាន និងចុងក្រោយត្រូវស្នើសុំវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវនៅពេលបញ្ចប់ការងារនៅការដ្ឋានពីអាជ្ញាធររួចមក នៅឆ្នាំ២០០១ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចេញ "ប្រកាសលេខ៣២ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់" ដែលប្រកាសនេះ បានតម្រូវបន្ថែមឱ្យម្ចាស់សំណង់ដាក់ពាក្យស្នើសុំលិខិតបិទការដ្ឋានសំណង់ក្រោយបញ្ចប់ការងារនៅការដ្ឋាន

លិខិតបទដ្ឋានគតិយុត្តសម្រាប់ការងារផ្តល់លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបិទការដ្ឋានរួមមាន÷

- អនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់
- អនុក្រឹត្យលេខ២២៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ២០២០ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់
- ប្រកាសលេខ ៣២ ប្រក/សណ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់
- ប្រកាសលេខ១០៩ ដនស/ប្រ.ក/នី.ក ចុះថ្ងៃទី២២ ខែ វិច្ឆិកា ឆ្នាំ២០២១ ស្តីពីបែបបទនៃការងារត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ស្ថាបត្យកម្មនិងគម្រោងប្លង់គ្រឿងផ្គុំសំណង់។

# លិខិតបទដ្ឋានគតិយុត្តសម្រាប់ការងារផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់

ក្រោយបញ្ចប់ការសាងសង់ ដើម្បីចូលប្រើប្រាស់សំណង់ ម្ចាស់សំណង់ត្រូវស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់។ យោងតាមច្បាប់ស្តីពីសំណង់ ការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ មាន២ប្រភេទគឺ៖

- ❖ ការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន និង
- ❖ ការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលសាងសង់រួចក្រោយច្បាប់ស្តីពីសំណង់ចូលជាធរមានស្របតាមនីតិវិធីនៃច្បាប់។

លិខិតបទដ្ឋានគតិយុត្តសម្រាប់ការងារផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ និងលិខិតបិទការដ្ឋានរួមមាន៖

- អនុក្រឹត្យលេខ២២៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ២០២០ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់
- ប្រកាសលេខ ៣២ ប្រក/សណ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់
- ប្រកាសលេខ១៧៧ ដនស/ប្រក ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីបែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន
- ប្រកាសលេខ១២៦ ដនស/ប្រ.ក/នី.ក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីបែបបទនៃការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ផ្នែកស្ថាបត្យកម្មនិងផ្នែកគ្រឿងផ្គុំសំណង់

**លិខិតបិទការដ្ឋាន?**

**វិញ្ញាបនបត្រប្រើប្រាស់សំណង់?**

✓ **លិខិតបិទការដ្ឋាន**

✓ **វិញ្ញាបនបត្រប្រើប្រាស់សំណង់ ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន**




✓ **លិខិតបិទការដ្ឋាន**

➢ **វិញ្ញាបនបត្រប្រើប្រាស់សំណង់ (មិនទាន់មានប្រកាសសម្រាប់អនុវត្ត)**

**សាងសង់រួចមុនថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩**

**សាងសង់រួចចាប់ពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩**

# ការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈ
# ក្នុងវិស័យសំណង់

# ការគ្រប់គ្រងការប្រកបអាជីវកម្ម

## អាជ្ញាបណ្ណក្នុងវិស័យសំណង់ (មាត្រា២០)

| | | |
|---|---|---|
| អាជ្ញាបណ្ណសិក្សាគម្រោងប្លង់ → | ក្រុមហ៊ុន | អ្នកវិជ្ជាជីវៈ |
| អាជ្ញាបណ្ណសាងសង់ → | ក្រុមហ៊ុន | អ្នកវិជ្ជាជីវៈ/ជាងជំនាញ/ក្រុមជាង |
| អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់ → | ក្រុមហ៊ុន | មន្ត្រីជំនាញ |
| អាជ្ញាបណ្ណមន្ទីរពិសោធន៍សំណង់ → | ក្រុមហ៊ុន | |
| អាជ្ញាបណ្ណគ្រប់គ្រងគម្រោងសាងសង់ → | ក្រុមហ៊ុន | |

# លិខិតបទដ្ឋានគតិយុត្តសម្រាប់ការធានាគ្រប់គ្រងអាជីវកម្មក្នុងវិស័យសំណង់

ការអនុវត្តការងារសំណង់មួយចំនួនដូចជា ការងារសិក្សាគម្រោងប្លង់ ការងារសាងសង់ ការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ ការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ជាដើម តម្រូវឱ្យមានអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រអនុញ្ញាតឱ្យប្រកបអាជីវកម្មដែលត្រូវផ្តល់ដោយក្រសួង ដនស។

ក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងក្រុមហ៊ុនសាងសង់ ត្រូវស្នើសុំវិញ្ញាបនបត្រអនុញ្ញាតឱ្យប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ និងវិញ្ញាបនបត្រអនុញ្ញាតឱ្យប្រកបអាជីវកម្មសាងសង់ពីក្រសួង ដនស ដោយអនុលោមតាមប្រកាសលេខ៧៥ ប្រក.ដ.ន.ស ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់។

នៅឆ្នាំ២០០៧ ក្រសួងក៏បានលើកកម្ពស់ការងារសិក្សាគម្រោងប្លង់ទៅដល់កម្រិតបុគ្គល តាមរយៈការអនុញ្ញាតឱ្យរូបវន្តបុគ្គលនីមួយៗ ដូចជាស្ថាបត្យករ និងវិស្វករសំណង់ស៊ីវិល អាចស្នើសុំវិញ្ញាបនបត្រអនុញ្ញាឱ្យប្រកបអាជីវកម្មសិក្សាគម្រោងប្លង់បានផងដែរ ដោយបានបែងចែកជាពកម្រិតដូចប្រភេទក្រុមហ៊ុន ហើយក៏មិនបានកំណត់អំពីវិសាលភាពការងារដូចគ្នា។

ក្រោយច្បាប់ស្តីពីសំណង់ចូលជាធរមាននៅឆ្នាំ២០១៩ ប្រព័ន្ធត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវបានបង្កើតឡើង ហើយអ្នកអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវមានអាជ្ញាបណ្ណពីក្រសួង ដនស។ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវបានតម្រូវឱ្យមានគុណវុឌ្ឍខ្ពស់ជាងអ្នកសិក្សាគម្រោងប្លង់ និងអ្នកសាងសង់ ដើម្បីធានានូវគុណភាពនិងសុវត្ថិភាពសំណង់ និងភាពស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។ ការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់នេះ ត្រូវបានកំណត់លក្ខខណ្ឌនិងនីតិវិធីនៅក្នុងអនុក្រឹត្យលេខ២២៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ រួមជាមួយនឹងបែបបទសម្រាប់អនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ និងការងារសាងសង់ផ្នែកស្ថាបត្យកម្មនិងផ្នែកគ្រឿងផ្គុំសំណង់ដែលកំណត់ដោយប្រកាសលេខ១០៩ និងប្រកាសលេខ១២៦ ឆ្នាំ២០២១ របស់ក្រសួង ដនស។

# លិខិតបទដ្ឋានគតិយុត្តសម្រាប់ការងារគ្រប់គ្រងអាជីវកម្មក្នុងវិស័យសំណង់

លិខិតបទដ្ឋានគតិយុត្តសម្រាប់ការងារគ្រប់គ្រងអាជីវកម្មក្នុងវិស័យសំណង់ រួមមាន÷

- អនុក្រឹត្យលេខ២២៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ២០២០ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់
- ប្រកាសលេខ៧៥ ប្រក/ដ.ន.ស ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាសនិងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់ (កែសម្រួលដោយប្រកាសលេខ១៦៦ ឆ្នាំ ២០០៧)
- ប្រកាសលេខ១៩២ ប្រក.ដនស/អសណ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគម្រោងប្លង់ (កែសម្រួលដោយប្រកាសលេខ០៣៥ ឆ្នាំ២០១០)
- ប្រកាសលេខ ០៣៣ ដ.ន.ស./ប្រ.ក.នី.ក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទ និងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់
- រាចរណែនាំលេខ ០០២ ដ.ន.ស/អ.ស.ណ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការចុះបញ្ជីប្រកបអាជីវកម្ម សិក្សាគម្រោងប្លង់ និង សាងសង់ របស់សហគ្រាស ក្រុមហ៊ុន និងរូបវន្តបុគ្គលបរទេស
- សេចក្តីជូនដំណឹងលេខ០៥ ដនស/អសណ ចុះថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគម្រោងប្លង់
- លិខិតលេខ ៣១៩ ដនស/អសណ/០៩ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩ ស្តីពីការកំណត់កាលបរិច្ឆេទនៃការចុះបញ្ជីរូបវន្តបុគ្គលសិក្សាគម្រោងប្លង់៕

# ការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈនិងអ្នកប្រកបអាជីវកម្មក្នុងវិស័យសំណង់

សម្រាប់ការគ្រប់គ្រងអ្នកប្រកបអាជីវកម្ម ចាប់ពីឆ្នាំ១៩៩៩ រហូតដល់បច្ចុប្បន្ន ក្រសួងអនុវត្តការងារដោយយោងតាមប្រកាស ប្រកាសលេខ៧៥ ឆ្នាំ១៩៩៩ ស្ដីពីការគ្រប់គ្រងសហគ្រាស ក្រុមហ៊ុនសិក្សាគំរោងប្លង់ និងសាងសង់។

ក្រុមហ៊ុនដែលបានចុះបញ្ជី នៅក្រសួងពាណិជ្ជកម្ម → ទទួលអាជ្ញាបណ្ណ ពី ជនស → អ្នកប្រកបអាជីវកម្មក្នុង វិស័យសំណង់

អ្នកអនុវត្តការងារនៅក្នុងក្រុមហ៊ុនដែលទទួលអាជ្ញាបណ្ណសម្រាប់ប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវតែអ្នកវិជ្ជាជីវៈ។

ស្ថាបត្យករ/វិស្វករ → ចុះបញ្ជីនៅគណៈ → អ្នកវិជ្ជាជីវៈ

ចំណែកការគ្រប់គ្រងអ្នកវិជ្ជាជីវៈឯករាជ្យ ត្រូវបានគ្រប់គ្រងដោយប្រកាសលេខ១៩២ ឆ្នាំ២០០៧ ស្ដីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគំរោងប្លង់។

## ការប្រែខ្លួនទៅជាអ្នកវិជ្ជាជីវៈដែលអាចប្រកបវិជ្ជាជីវៈដោយឯករាជ្យ

អ្នកវិជ្ជាជីវៈ → ទទួលអាជ្ញាបណ្ណពី ជនស → អ្នកវិជ្ជាជីវៈដែលអាចប្រកបវិជ្ជាជីវៈដោយឯករាជ្យ

# ការគ្រប់គ្រងការដ្ឋានសំណង់

# លិខិតបទដ្ឋានគតិយុត្តសម្រាប់ការងារគ្រប់គ្រងការដ្ឋានសំណង់

ក្រោយមានលិខិតបទដ្ឋានគតិយុត្ត សម្រាប់គ្រប់គ្រងទៅលើការងារសំណង់ តាមរយៈការតម្រូវឱ្យម្ចាស់សំណង់ស្នើសុំលិខិតអនុញ្ញាតសាងសង់និងលិខិតអនុញ្ញាតបើកការដ្ឋានសំណង់មុននឹងចាប់ផ្តើមដំណើរការសាងសង់នៅការដ្ឋាន ហើយត្រូវសុំលិខិតបិទការដ្ឋានក្រោយពីបញ្ចប់ការងារនៅការដ្ឋានក្តី ក៏ការសាងសង់ដោយគ្មានលិខិតអនុញ្ញាតទាំងនេះ ឬមានលិខិតអនុញ្ញាតហើយ ប៉ុន្តែសាងសង់មិនស្របតាមការអនុញ្ញាត បានកើតឡើងជាហូរហែរ។ លិខិតបទដ្ឋានគតិយុត្តសម្រាប់ការងារគ្រប់គ្រងការដ្ឋានសំណង់ រួមមាន÷

- ប្រកាសលេខ ៣២ ប្រក/សណ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់
- ប្រកាសរួមលេខ ១២២៩ ប្រក.មផ.ដនស ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៩ ស្តីពីការទប់ស្កាត់ការសាងសង់គ្មានលិខិតអនុញ្ញាត ឬ ការសាងសង់ខុសពីលិខិតអនុញ្ញាត
- ប្រកាសលេខ ០៨៥ ដនស/ប្រក/អសណ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីសុខភាពនិងសុវត្ថិភាពនៅការដ្ឋានសំណង់
- លិខិតលេខ៥១៣ ដនស/អរប/នីក ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០២២ ស្តីពីការហាមឃាត់ការសាងសង់ឬរុះរើសំណង់ដែលមិនទាន់ទទួលបានលិខិតអនុញ្ញាត
- លិខិតលេខ៥២០ ដនស/អរប/នី.ក ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២២ ស្តីពីការទប់ស្កាត់ការសាងសង់ឬរុះរើសំណង់ដែលគ្មានលិខិតអនុញ្ញាត
- លិខិតលេខ៨៩៧ ដនស/អរប/នី.ក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២២ ស្តីពីការហាមឃាត់វិស្វករមិនឱ្យទទួលអនុវត្តការងារសាងសង់ឬរុះរើដែលមិនទាន់មានលិខិតអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច
- លិខិតលេខ៨៩៨ ដនស/អរប/នី.ក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២២ ស្តីពីការហាមឃាត់ស្ថាបត្យករមិនឱ្យទទួលអនុវត្តការងារសាងសង់ឬរុះរើដែលមិនទាន់មានលិខិតអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

# គោលការណ៍ណែនាំស្តីពីសុខភាពនិងសុវត្ថិភាពនៅការដ្ឋានសំណង់

គោលការណ៍ណែនាំនេះ ត្រូវបានដាក់ឱ្យប្រើប្រាស់តាមរយៈប្រកាសលេខ ០៨៥ ដនស/ប្រ.ក/អសណ ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការប្រកាសដាក់ឱ្យប្រើគោលការណ៍ណែនាំស្តីពីសុខភាពនិងសុវត្ថិភាពនៅការដ្ឋានសំណង់ ដើម្បីបញ្ចៀសគ្រោះថ្នាក់ដែលអាចកើតមានឡើងជាយថាហេតុនៅតាមការដ្ឋានសំណង់និងដែលអាចធ្វើឱ្យបង្កផលប៉ះពាល់ដល់សុខភាពនិងអាយុជីវិតរបស់កម្មករ និយោជិតដែលធ្វើការនៅការដ្ឋានសំណង់ សាធារណជន និងផែនការនៃគម្រោងសាងសង់។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
ប្រកាស
ស្តីពី


សម្រេច



# ការងារចុះត្រួតពិនិត្យការដ្ឋាន និងដោះស្រាយវិវាទសំណង់

- ការងារចុះត្រួតពិនិត្យការដ្ឋានសំណង់
  - បានចុះត្រួតពិនិត្យការដ្ឋានសំណង់តាមសំណើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ លិខិតបិទការដ្ឋានសំណង់ និងលិខិតអនុញ្ញាតជួសជុល និងដើម្បីដោះស្រាយវិវាទសំណង់ សរុបចំនួន ១២ ១៣៦ ការដ្ឋាន (ក្នុងនោះថ្នាក់ជាតិ : ៤ ១៥៣ ការដ្ឋាន និងថ្នាក់ក្រោមជាតិ : ៧ ៩៨៣ ការដ្ឋាន)
- ការងារដោះស្រាយវិវាទសំណង់
  - បានទទួលពាក្យបណ្ដឹងអំពីវិវាទសំណង់ ចំនួន ១៣៥ ករណី
  - បានដោះស្រាយបញ្ចប់ជាស្ថាពរ ចំនួន ៥៦ ករណី
  - កំពុងបន្តដោះស្រាយ ចំនួន ៣៩ ករណី
  - បានផ្អាកការដ្ឋាន ចំនួន ១១ ករណី
  - បានបញ្ជូនទៅអគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រ ចំនួន ១ ករណី
  - បានបញ្ជូនទៅរដ្ឋបាលរាជធានី-ខេត្ត ដោះស្រាយជាសមត្ថកិច្ច ចំនួន ១១ ករណី
  - បានបញ្ជូនទៅមន្ទីរ ដ.ន.ស.ស. រាជធានី-ខេត្ត ដោះស្រាយជាសមត្ថកិច្ច ចំនួន ១៤ ករណី
  - បានបញ្ជូនទៅស្ថាប័នតុលាការ ចំនួន ៣ ករណី។

# ការងារផ្តល់សេវាសាធារណៈពីឆ្នាំ២០១៨ ដល់ ខែកក្កដា ឆ្នាំ២០២៣

| ការផ្តល់លិខិតអនុញ្ញាតសាងសង់ | | | | | | | |
|---|---|---|---|---|---|---|---|
| រយៈពេល | ចំនួនគម្រោង | | ផ្ទៃក្រឡា (ម$^{2}$) | | ទុនវិនិយោគ | | |
| | ទូទាំងប្រទេស | ថ្នាក់ក្រសួង | ទូទាំងប្រទេស | ថ្នាក់ក្រសួង | ទូទាំងប្រទេស | | ថ្នាក់ក្រសួង |
| 2018 | **3,290** | 257 | **12,378,119** | 11,029,399 | $ | **5,755,070,120.00** | 5,258,149,607 |
| 2019 | **4,888** | 500 | **23,257,414** | 20,318,973 | $ | **11,437,267,145.00** | 10,433,113,441 |
| 2020 | **4,841** | 441 | **29,425,751** | 26,241,989 | $ | **7,753,349,289.00** | 6,651,321,414 |
| 2021 | **4,303** | 388 | **12,998,072** | 10,420,293 | $ | **5,333,798,525.00** | 4,218,910,127 |
| 2022 | **4,276** | 226 | **7,289,765** | 5,659,006 | $ | **2,972,260,928.00** | 2,358,756,638 |
| 2023(7ខែ) | **2,036** | 211 | **8,000,258** | 7,232,450 | $ | **3,199,806,581.00** | 2,921,404,679 |
| 2018-2023(7ខែ) | 23,634 | 2,023 | 93,349,379.00 | 80,902,110.00 | $ | 36,451,552,588.00 | $ 31,841,655,906.00 |
| 2000-2023(7ខែ) | 63,903 | | 181,876,844.00 | | $ | 72,374,619,215.00 | |




- បានផ្តល់លិខិតអនុញ្ញាត**បើកការដ្ឋានសំណង់**ចំនួន **៩២៩ គម្រោង** (សរុប **២ ៤០៩ គម្រោង**)
- បានផ្តល់លិខិត**បិទការដ្ឋានសំណង់**ចំនួន **៥៦៨ គម្រោង** (សរុប **១ ១០៩ គម្រោង**)
- បានផ្តល់លិខិត**អនុញ្ញាតជួសជុល**ចំនួន **៧៧ គម្រោង** (សរុប **២២៤ គម្រោង**)
- បានផ្តល់**វិញ្ញាបនបត្រប្រើប្រាស់សំណង់**ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន **ចំនួន ៣០គម្រោង**
- បានផ្តល់អាជ្ញាបណ្ណរូបវន្តបុគ្គលសិក្សាគម្រោងប្លង់ចំនួន **៦២៨នាក់** (សរុប **៦៥០នាក់ និងនៅមានសុពលភាព ៣៨៥**)
- បានផ្តល់អាជ្ញាបណ្ណ**ក្រុមហ៊ុនសិក្សាគម្រោងប្លង់**ចំនួន **១២៤** (សរុប **១៦៧ និងនៅមានសុពលភាព ៦៤**)
- បានផ្តល់អាជ្ញាបណ្ណ**ក្រុមហ៊ុនសាងសង់**ចំនួន ២១៥៧ (សរុប **៣២៣៦ និងនៅមានសុពលភាព១០០៧**)
- បានផ្តល់អាជ្ញាបណ្ណក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ចំនួន **៦** (សរុប **៦ និងនៅមានសុពលភាព៦**)។

# ការចូលរួមគាំទ្រវិស័យសំណង់ និងអចលនវត្ថុ

## ប្រកាសលេខ០៨៣ ដនស/ប្រ.ក/នី.ក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣ ស្តីពីការលុបប្រកាស ស្តីពីការអភិវឌ្ឍដី ឆ្នាំ២០១៨






# ការចូលរួមគាំទ្រវិស័យសំណង់ និងអចលនវត្ថុ

## ការលើកលែងការបង់ថ្លៃសេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ក្រោយពីទទួលបានគោលការណ៍ពីរាជរដ្ឋាភិបាលនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៣ ការស្នើសុំសាងសង់អគារមន្ទីរពេទ្យឯកជន អគារសាលារៀនឯកជន និងអគារលំនៅឋានតម្លៃសមរម្យ ការស្នើសុំគោលការណ៍សាងសង់ លិខិតអនុញ្ញាតសាងសង់ និងលិខិតអនុញ្ញាតសាងសង់លើសកម្រិតសន្ទស្សន៍ប្រើប្រាស់ដីអតិបរមាផ្លូវការ ត្រូវបានលើកលែងការបង់ថ្លៃសេវាសាធារណៈ តាមរយៈប្រកាសអន្តរក្រសួងលេខ ៣១២ សហវ.ប្រ.ក.អទច ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣ ។




ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ប្រកាសអន្តរក្រសួង
ស្តីពី
ការលើកលែងការបង់ថ្លៃសេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់


សម្រេច





# ការចូលរួមគាំទ្រវិស័យសំណង់ និងអចលនវត្ថុ

## ៤. ការស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់សម្រាប់សំណង់អគាររោងចក្រ និងឃ្លាំង ដែលមានសាងសង់រួចមុនច្បាប់សំណង់ចូលជាធរមាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ : ០០១ ដនសស/ប្រក/សរចណ

**សេចក្តីជូនដំណឹង**
**ស្តីពីការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់អគាររោងចក្រនិងឃ្លាំង**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ម្ចាស់អគាររោងចក្រឬឃ្លាំងទាំងអស់ជ្រាបថា អនុលោមតាមប្រកាសលេខ១៧៧ ដនស/ប្រក ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីបែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន ម្ចាស់អគាររោងចក្រឬឃ្លាំងដែលមិនទាន់មានលិខិតបិទការដ្ឋានសំណង់ឬវិញ្ញាបនបត្រប្រើប្រាស់សំណង់ អាចមកស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមអញ្ជើញម្ចាស់អគាររោងចក្រឬឃ្លាំងដូចមានចែងក្នុងកម្មវត្ថុខាងលើ មកដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ នៅច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធចាំបាច់ ដើម្បីក្រុមការងារជួយពិនិត្យនិងចាត់ចែងជូន។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖

- លោក ទេព ង៉ែតពិសាល ០៦៦ ៥៧៩ ៥៧៩
- លោក ផូរ ច័ន្ទភក្តី ០៩៥ ៨៦៤ ៤៨៧

ថ្ងៃពុធ ១កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣

អាសយដ្ឋាន : ដីឡូត៍លេខ ២០០៥ ផ្លូវលេខ ៣០៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ (855) 23 886 999 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

ប្រកាសលេខ ១៧៧ ឆ្នាំ ២០១៩ សម្រាប់សំណង់ទូទៅ មានឯកសារតម្រូវចំនួន ១១



សេចក្តីជូនដំណឹងរបស់ក្រសួង
នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣ ចំនួនតែ ៥ ប៉ុណ្ណោះ

# ការចូលរួមគាំទ្រវិស័យសំណង់ និងអចលនវត្ថុ

## ៥. សេចក្តីប្រកាសព័ត៌មានរបស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខ០០១ សហវ ចុះថ្ងៃទី១២ ខែមេសា រ ២០២៣ ស្តីពីសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលអំពីវិធានការគាំទ្រដល់ការអភិវឌ្ឍវិស័យសំណង់ និងអចលនវត្ថុផ្នែកបុរី



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០០១........សហវ.......

ថ្ងៃ ពុធ ៧កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែមេសា ឆ្នាំ ២០២៣

**សេចក្តីប្រកាសព័ត៌មាន**
**របស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ស្តីពីសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា**
**អំពីវិធានការគាំទ្រដល់ការអភិវឌ្ឍវិស័យសំណង់ និងអចលនទ្រព្យផ្នែកបុរី**

ទោះបីសកម្មភាពសង្គម-សេដ្ឋកិច្ចកម្ពុជាបាន និងកំពុងបើកឡើងវិញជាបណ្តើរៗ តាមគន្លងប្រក្រតីភាពថ្មីក៏ដោយ បច្ចុប្បន្ន ដូចបណ្តាប្រទេសនានា ការកើនឡើងនូវភាពមិនប្រាកដប្រជាខ្ពស់នៃស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុសកល នៅតែជាក្តីកង្វល់ដ៏ធំចំពោះកំណើនសេដ្ឋកិច្ចជាតិ ជាពិសេសហានិភ័យនៃការងើបឡើងវិញយឺតជាងការព្យាកររបស់សេដ្ឋកិច្ចសកល, ការកើនឡើងនូវភាពតានតឹងនៃសង្គ្រាមរវាងរុស្ស៊ីនិងអ៊ុយក្រែន, ការរឹតបន្តឹងយូរជាងការរំពឹងទុកនៃគោលនយោបាយរូបិយវត្ថុក្នុងប្រទេសកំពុងអភិវឌ្ឍន៍, ការបន្តអាក់រអួលនៃខ្សែច្រវាក់ផ្គត់ផ្គង់សកល និង ការកើនឡើងនូវភាពតានតឹង នៃវិស័យហិរញ្ញវត្ថុសកលជាដើម ។ ក្នុងន័យនេះ ដើម្បីរក្សាស្ថិរភាពនៃវិស័យសំណង់ និងអចលនទ្រព្យ ដែលត្រូវបានចាត់ទុកជាវិស័យអាទិភាពមួយក្នុងការគាំទ្រដល់កំណើនសេដ្ឋកិច្ចជារួម, ជាពិសេស បន្តរក្សានិរន្តរភាពការងារជូនបងប្អូនកម្មករ ព្រមទាំងលើកកម្ពស់លទ្ធភាពដល់ប្រជាពលរដ្ឋដែលមានចំណូលទាប និងមធ្យម អាចមានលទ្ធភាពទិញលំនៅឋានតម្លៃសមរម្យបាន, រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវវិធានការបន្ថែម **ជាកញ្ចប់** ដូចខាងក្រោម៖

**ទី១.** បន្តពន្យារពេលការអនុវត្តការបង់ពន្ធជាកញ្ចប់តាមដំណាក់កាលរហូតដល់ដំណាច់ឆ្នាំ ២០២៤ សម្រាប់ក្រុមហ៊ុនអភិវឌ្ឍន៍លំនៅឋានជាបុរីដែលបាន និងកំពុងប្រតិបត្តិការគម្រោងអភិវឌ្ឍន៍លំនៅឋានដែលមានអាជ្ញាបណ្ណអាជីវកម្មអចលនវត្ថុ ផ្តល់ដោយនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ ។ ដោយឡែក ក្រុមហ៊ុនដែលបាន និងកំពុងប្រតិបត្តិការគម្រោងអភិវឌ្ឍន៍លំនៅឋានជាបុរី ដែលគ្មានអាជ្ញាបណ្ណអាជីវកម្មអចលនវត្ថុ ត្រូវរួសរាន់ចុះបញ្ជីគម្រោងរបស់ខ្លួន ដើម្បីទទួលបានអាជ្ញាបណ្ណអាជីវកម្មអចលនវត្ថុ ស្របតាមនីតិវិធីជាធរមានពីនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំយ៉ាងយូរត្រឹមដំណាច់ឆ្នាំ ២០២៣ ដើម្បីទទួលបានការបន្តការបង់ពន្ធជាកញ្ចប់រហូតដល់ដំណាច់ឆ្នាំ ២០២៤ ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia

ទំព័រទី ១ នៃ ២៥

Phone: (855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

វិធានការចំនួន ៨ចំណុច សម្រាប់គាំទ្រដល់ការអភិវឌ្ឍវិស័យសំណង់ និងអចលនវត្ថុផ្នែកបុរី (ភាគច្រើនផ្នែកលើកទឹកចិត្តការបង់ពន្ធ)



# ការកសាងគោលនយោបាយ
# និងលិខិតបទដ្ឋានគតិយុត្ត

# ការកសាងគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត

- សេចក្តីព្រាង គោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យសំណង់កម្ពុជា ២០២៥-២០៣៥
  *ដើម្បីឈានឆ្ពោះទៅរកការបំភាយកាបូនសូន្យប្រកបដោយប្រសិទ្ធភាព និងភាពធន់នៃសំណង់ និងសំដៅសម្រេចបានចក្ខុវិស័យសំណង់កម្ពុជាឆ្នាំ ២០៥០*
- សេចក្តីព្រាង យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសំណង់ឱ្យជីថល ២០២៣-២០២៨
- សេចក្តីព្រាង ផែនទីបង្ហាញផ្លូវឆ្ពោះទៅការបញ្ចេញកាបូនទាប និងធន់នឹងអាកាសធាតុក្នុងវិស័យសំណង់អគារ នៅកម្ពុជា ចក្ខុវិស័យឆ្នាំ ២០៥០



សេចក្តីព្រាង

រាជរដ្ឋាភិបាលកម្ពុជា

សេចក្តីព្រាង

គោលនយោបាយជាតិ
ស្តីពី
ការអភិវឌ្ឍវិស័យសំណង់កម្ពុជា
២០២៥-២០៣៥

" ដើម្បីឈានឆ្ពោះទៅរកការបំភាយកាបូនសូន្យប្រកបដោយប្រសិទ្ធភាព និងភាពធន់នៃសំណង់ និងសំដៅសម្រេចបានចក្ខុវិស័យសំណង់កម្ពុជាឆ្នាំ ២០៥០"

ភ្នំពេញ, ថ្ងៃព្រហស្បតិ៍ ទី ២៧ ខែមករា ឆ្នាំ ២០២២



រាជរដ្ឋាភិបាលកម្ពុជា

សេចក្តីព្រាង

យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសំណង់ឌីជីថល
ឆ្នាំ ២០២៣-២០២៨

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
អគ្គនាយកដ្ឋានសំណង់

ថ្ងៃចន្ទ ៤ កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០២២



ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
Ministry of Land Management, Urban Planning and Construction

ផែនទីបង្ហាញផ្លូវឆ្ពោះទៅការបញ្ចេញកាបូនទាប និងធន់នឹងអាកាសធាតុ ក្នុងវិស័យសំណង់អគារ នៅកម្ពុជា
ចក្ខុវិស័យឆ្នាំ២០៥០

២០២២

គាំទ្រដោយ៖ កម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)

# ការអភិវឌ្ឍបទដ្ឋានបច្ចេកទេសសំណង់

- សេចក្តីព្រាង គោលការណ៍ណែនាំបច្ចេកទេសស្តីពីការរៀបចំអាងស៊ិបទឹក អាងប្រព្រឹត្តិកម្មទឹកកខ្វក់ និងអាងប្រព្រឹត្តិកម្មសំណល់រាវក្នុងវិស័យសំណង់
- សេចក្តីព្រាង គោលការណ៍ណែនាំបទដ្ឋានស្តង់ដាស្ថាបត្យកម្ម (Ernst and Neufert 9th Edition)
- ការប្រែសម្រួលបទដ្ឋានបច្ចេកទេសសំណង់ផ្នែកគ្រឿងផ្គុំសំណង់អំពីបេតុង (ACI 318M-19)
- ការប្រែសម្រួលបទដ្ឋានបច្ចេកទេសសំណង់ផ្នែកគ្រឿងផ្គុំសំណង់អំពីដែក ( AISC 360-16)












# ការអភិវឌ្ឍបទដ្ឋានបច្ចេកទេសសំណង់

- សេចក្តីព្រាង បទដ្ឋានបច្ចេកទេសសំណង់ផ្នែកសុវត្ថិភាពគ្រឿងផ្គុំសំណង់ និងផ្នែកសុវត្ថិភាពអគ្គិភ័យ ( MLIT- JICA)
- គម្រោងគំនិតផ្តួចផ្តើម វិធីសាស្ត្រសម្រាប់ការវាយតម្លៃសុវត្ថិភាពបឋមនៅកម្ពុជា
- គម្រោងគំនិតផ្តួចផ្តើម បទដ្ឋានសុវត្ថិភាពគ្រោងអគារ អគ្គិភ័យ និងអគ្គិសនីយនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង កាបូប និងផលិតផលធ្វើដំណើរ
- កម្រងព័ត៌មានស្តីពីសាធាតុ អាបេស្តុស Asbestos ក្នុងសំណង់អគារ















# ការបណ្តុះបណ្តាល និងការអប់រំផ្សព្វផ្សាយ

- ផ្សព្វផ្សាយពាក់ព័ន្ធនឹងការងារសំណង់ ចំនួន ១៩វគ្គ ដល់អ្នកពាក់ព័ន្ធសរុបចំនួន **៤ ៥៩០** នាក់
- បណ្តុះបណ្តាលច្បាប់ស្តីពីសំណង់ និងបណ្តុះបណ្តាលគ្រូបង្គោលស្តីពីជំនាញច្បាប់ស្តីពីសំណង់ សរុបចំនួន ២លើក ដែលមានសិក្ខាកាមចូលរួមចំនួន **៥៨១**នាក់
- បណ្តុះបណ្តាលស្តីពីការបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌សម្រាប់អនុវត្តការងារអធិការកិច្ចសំណង់ សរុបចំនួន ៣លើក ដែលមានសិក្ខាកាមចូលរួមសរុបចំនួន **៣៥៧នាក់**
- ផ្សព្វផ្សាយគោលការណ៍ណែនាំស្តីពីសុខភាពនិងសុវត្ថិភាពនៅការដ្ឋានសំណង់ចំនួន ៤តំបន់ ទូទាំងប្រទេស ដល់អាជ្ញាធរដែនដី មន្ត្រីជំនាញ អ្នកប្រកបអាជីវកម្មនិងអ្នកប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់ និងអ្នកពាក់ព័ន្ធ សរុបចំនួន **៤០៧**នាក់
- ផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យសំណង់ សរុបចំនួន **៤១វគ្គ** ដែលមានអ្នកចូលរួមប្រមាណ **៨ ១៧០**នាក់។

**សរុបបណ្តុះបណ្តាលនិងផ្សព្វផ្សាយចំនួន៤៦លើក/វគ្គ និងមានសិក្ខាកាម/អ្នកចូលរួមចំនួន ១៤ ១០៥នាក់។**

# បរិវត្តកម្មឌីជីថលក្នុងវិស័យសំណង់

# បរិវត្តកម្មឌីជីថលក្នុងវិស័យសំណង់

## ១. កម្មវិធីព័ត៌មានវិទ្យា “សំណង់នៅកម្ពុជា (Cambodia Construction Information)”













CCI ជាកម្មវិធីព័ត៌មានវិទ្យាដែលផ្ដល់ព័ត៌មានពាក់ព័ន្ធនឹងលិខិតអនុញ្ញាតសាងសង់ក្រោមសមត្ថកិច្ចរបស់ក្រសួងនៅលើទូរស័ព្ទដៃទំនើប (G4C)។

## ២. ប្រព័ន្ធតាមដានចរន្តឯកសារផ្ដល់សេវាសាធារណៈ: (Document Tracking System) (G2G)




Document Tracking ជាកម្មវិធីសម្រាប់អនុវត្តតាមដានចរន្តកិច្ចការរដ្ឋបាលផ្ទៃក្នុងរបស់អគ្គនាយកដ្ឋានសំណង់ ដែលបច្ចុប្បន្ននេះកំពុងអនុវត្តសាកល្បងទៅលើការផ្ដល់លិខិតអនុញ្ញាតបើកការដ្ឋានសំណង់។

# បរិវត្តកម្មឌីជីថលក្នុងវិស័យសំណង់

## ៣. កម្មវិធីព័ត៌មានវិទ្យាចុះត្រួតពិនិត្យការដ្ឋានសំណង់ដោយប្រើឧបករណ៍ថេបប្លេត (Tablet)









ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កំណត់ហេតុ


អ្នកធ្វើកំណត់ហេតុ

បានឃើញនិងយល់ព្រម

ម្ចាស់សំណង់ | អ្នកសាងសង់ | វិស្វករប្រចាំការដ្ឋាន

បានឃើញនិងឯកភាព

ប្រធានក្រុមការងារចុះត្រួតពិនិត្យការដ្ឋានសំណង់

# បរិវត្តកម្មឌីជីថលក្នុងវិស័យសំណង់

## ៤. ប្រព័ន្ធគ្រប់គ្រងទិន្នន័យសំណង់

***ប្រព័ន្ធនេះត្រូវបានរចនាឡើងជា២ផ្នែក គឺផ្នែកខាងឆ្វេងសម្រាប់គ្រប់គ្រងរួម និងផ្នែកខាងស្ដាំសម្រាប់បង្ហាញព័ត៌មានលម្អិត។***

- ទំព័រដើម បង្ហាញចំណងជើង *"ប្រព័ន្ធគ្រប់គ្រងសំណង់កម្ពុជា"* និងទិន្នន័យរួមមានលក្ខណៈសង្ខេបអំពីសំណង់ស្ថិតនៅក្រោមសមត្ថកិច្ចក្រសួង និងរដ្ឋបាលរាជធានី ខេត្ត ដូចខាងក្រោម÷
  - គម្រោង
  - ទុនវិនិយោគ
  - អ្នកវិជ្ជាជីវៈសិក្សាគម្រោងប្លង់
  - ក្រុមហ៊ុនសិក្សាគម្រោងប្លង់
  - ក្រុមហ៊ុនសាងសង់
  - អ្នកត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់
  - អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់។
- នៅក្នុងប្រអប់នីមួយៗ បង្ហាញនូវទិន្នន័យសរុប ទិន្នន័យក្នុងឆ្នាំ និងក្នុងខែកំពុងប្រតិបត្តិ។ ទិន្នន័យទាំងអស់នេះត្រូវបានចងភ្ជាប់ជាមួយនឹងទិន្នន័យនៅតាមផ្នែកនីមួយៗ ដែលបច្ចុប្បន្នភាពជានិច្ច។
- តាមរយៈប្រអប់បង្ហាញទិន្នន័យទាំងនេះ អាចចុចបន្តដើម្បីឆ្ពោះទៅរកព័ត៌មានបន្ថែមតាមផ្នែកនីមួយៗនោះវិញផងដែរ។
- នៅខាងក្រោម មានទិន្នន័យកាន់តែលម្អិតបន្ថែមពីប្រអប់នៅផ្នែកខាងលើ។



# បរិវត្តកម្មឌីជីថលក្នុងវិស័យសំណង់

## ប្រព័ន្ធគ្រប់គ្រងទិន្នន័យសំណង់



# បរិវត្តកម្មឌីជីថលក្នុងវិស័យសំណង់

## ប្រព័ន្ធគ្រប់គ្រងទិន្នន័យសំណង់

**សំណង់÷ សមត្ថកិច្ចក្រសួង និងរដ្ឋបាលរាជធានី ខេត្ត (ត)**

- ផែនទី÷ ក្រៅពីតារាងសំណង់ដោយទីតាំងដែលបង្ហាញពីចំនួនសំណង់នៅតាមរាជធានី ខេត្តនីមួយៗ និងតារាងសំណង់នៅតាមបណ្តារាជធានី ខេត្តដែលបង្ហាញសំណង់គ្មានលិខិតអនុញ្ញាតសំណង់មានលិខិតបើក/បិទការដ្ឋានតាមបណ្តារាជធានី ខេត្ត កម្មវិធីនេះក៏ផ្តល់លទ្ធភាពឱ្យស្វែងរកទីតាំងការដ្ឋានសំណង់ជាក់ស្តែងនៅក្នុង Google Maps ផងដែរ (មាននៅក្នុងផ្នែក សំណង់ក្រោមសមត្ថកិច្ចក្រសួង និងរាជធានី ខេត្ត)។

មើលតាម Google Map

មើលតាម Satellite






# បរិវត្តកម្មឌីជីថលក្នុងវិស័យសំណង់

## (Digital Platform for Modelling 3D Digital City)

- **ជំហានទី១ ÷** អគ្គនាយកដ្ឋានសំណង់បានអនុវត្តគម្រោងសាកល្បងគម្រូប្លង់នេត្រាទស្សន៍ឌីជីថលក្រុងសៀមរាបដែលមានទំហំ២៨២០០ ហិកតា និងផលិតបានជាផែនទីអរតូហ្វូតូខ្នាត ១÷៤៥០០ ជូនក្រុមការងារនៃគណៈកម្មការអន្តរក្រសួងដើម្បីសិក្សា និងអនុវត្តគម្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវចំនួន៣៨ខ្សែនៅក្រុងសៀមរាប ខេត្តសៀមរាប។







# បរិវត្តកម្មឌីជីថលក្នុងវិស័យសំណង់

## ៥. ថ្នាលឌីជីថលសម្រាប់អនុវត្តគម្រូប្លង់ឌីជីថលសម្រាប់ទីក្រុង

(Digital Platform for Modelling 3D Digital City)

**ជម្រើសបច្ចេកវិទ្យាផែនទី ពីលើអាកាស** (Aerial Survey) **និងនៅលើដី** (Mobile Mapping)

រូបភាពផ្កាយរណប



LiDAR Scan



A lidar intensity map image of Angkor Wat



ភាពជាក់លាក់ XYZ បច្ចេកទេស
ឧបករណ៍មានតំលៃខ្ពស់

Photogrammetry





រូបភាពល្អក្នុងការបង្ហាញ
ឧបករណ៍មានតំលៃសមរម្យ

# បរិវត្តកម្មឌីជីថលក្នុងវិស័យសំណង់

## ថ្នាលឌីជីថលសម្រាប់អនុវត្តគម្រូប្លង់ឌីជីថលសម្រាប់ទីក្រុង (ត)

- **ជំហានទី៣**÷ការរៀបចំនិងកសាងហេដ្ឋារចនាសម្ព័ន្ធដើម្បីបម្រើដល់ការប្រើប្រាស់ថ្នាលឌីជីថលសម្រាប់អនុវត្តគម្រូប្លង់ឌីជីថលសម្រាប់ទីក្រុងឱ្យបានពេញលេញ ដោយឈរលើគោលការណ៍ចំនួន៤ គឺ÷
  - ភាពជាម្ចាស់ការក្នុងការគ្រប់គ្រងទិន្នន័យ
  - សុវត្ថិភាពទិន្នន័យនិងកម្មវិធី
  - ការអភិវឌ្ឍធនធានមនុស្ស និង
  - ប្រសិទ្ធភាពនិងភាពជឿទុកចិត្តក្នុងការប្រើប្រាស់កម្មវិធី។



- ការប្រើប្រាស់ថ្នាលឌីជីថលផែនទីនេត្រាទស្សន៍នឹងឈានទៅដល់ការបម្រើសេវារវាងស្ថាប័នរដ្ឋជាមួយស្ថាប័នរដ្ឋ (G2G) ស្ថាប័នរដ្ឋជាមួយវិស័យឯកជន (G2B) និងស្ថាប័នរដ្ឋជាមួយប្រជាពលរដ្ឋ (G4C) តាមរយៈវិស័យមួយចំនួនដូចជា÷
  - វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
  - វិស័យសេដ្ឋកិច្ច (ការងារពន្ធដារ)
  - វិស័យកសិកម្ម
  - វិស័យធនធានទឹក និងឧតុនិយម
  - វិស័យគ្រប់គ្រងគ្រោះមហន្តរាយ
  - វិស័យសាធារណការ និងគមនាគមន៍
  - វិស័យថាមពល (ការងារគម្រូប្រើប្រាស់ថាមពល)
  - វិស័យសន្តិសុខ និងសណ្តាប់ធ្នាប់
  - វិស័យផែនការ (ការងារប្រជាសាស្ត្រ) និង
  - វិស័យទេសចរណ៍។ល។

# បរិវត្តកម្មឌីជីថលក្នុងវិស័យសំណង់

## ថ្នាលឌីជីថលសម្រាប់អនុវត្តគម្រូបច្ចេកឌីជីថលសម្រាប់ទីក្រុង (ត)

ការប្រើប្រាស់ថ្នាលឌីជីថលផែនទីនេត្រាទស្សន៍តាមវិស័យ នីមួយៗ នឹងត្រូវបោះជំហានពីការប្រើប្រាស់ប្រព័
ព័ត៌មានវិទ្យាទៅជាការប្រើប្រាស់បញ្ញាសិប្បនិម្មិត្ត (Artificial Intelligence) ដែលជាឧបករណ៍ជំនួយមួយក្នុ
ការគ្រប់គ្រង និងវិភាគទិន្នន័យដែលជាទិន្នន័យធំ (Big Data)។





QR Code សម្រាប់ចូលក្នុងក្រុមតេលេក្រាម

# “ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធក្នុងវិស័យសំណង់”

ច្បាប់

និងលិខិតបទដ្ឋានគតិយុត្ត

ពាក់ព័ន្ធនឹងវិស័យសំណង់



អរគុណសន្តិភាព!